


# តើអ្វីជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌?

## និយមន័យ



សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌គឺជាសិទ្ធិស្នូលក្នុងប្រព័ន្ធយុត្តិធម៌។ ក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ផ្តល់សិទ្ធិឱ្យជនគ្រប់រូបដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌទទួលបានការកាត់ក្តីដោយយុត្តិធម៌ និងស្មើភាព ខណៈដែលរដ្ឋកំណត់ពីភាពមានពិរុទ្ធភាព និងភាពគ្មានទោស។

សិទ្ធិនេះ រួមមានសិទ្ធិផ្សេងៗមួយចំនួនរបស់បុគ្គលម្នាក់ៗ ដែលហៅជារួមថា"សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" ដែលរួមមានជាអាទិ៍នូវសិទ្ធិដូចខាងក្រោម៖

- សិទ្ធិទទួលការជំនុំជម្រះជាសាធារណៈ
- សិទ្ធិមានវត្តមាននៅពេលសវនាការ
- សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស
- សិទ្ធិប្តឹងតវ៉ាទៅកាន់តុលាការជាន់ខ្ពស់លើផ្នែកអង្គហេតុ និងអង្គច្បាប់។
- សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី
- សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល។
- សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ និងមានសំអាងហេតុ
- សិទ្ធិមានមេធាវី
- សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់
- សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង

# ក្របខ័ណ្ឌច្បាប់

## ច្បាប់អន្តរជាតិ

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានទទួលស្គាល់ជាអន្តរជាតិតាមមាត្រា ១០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស៖ "មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នានិងពេញលេញក្នុងការសុំឱ្យតុលាការឯករាជ្យ និងមិនលម្អៀង ត្រួតពិនិត្យរឿងក្តីរបស់ខ្លួនជាសាធារណៈ និងដោយសមធម៌ ដើម្បីសម្រេចបានលើសិទ្ធិកាតព្វកិច្ច និងភាពសមហេតុផលចំពោះការចោទប្រកាន់បទព្រហ្មទណ្ឌនានា"។ សិទ្ធិនេះក៏ត្រូវបានចែងនៅក្នុងច្បាប់អន្តរជាតិជាច្រើនរួមមានមាត្រា ១៤ នៃ ("ក.ស.អ. ព.ន") និងមាត្រា ៤០ (២)(ខ)(iii) នៃ ("អ.ស.ក")។



## ច្បាប់ជាតិ



សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានការពារយ៉ាងច្បាស់នៅក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា "ច្បាប់រ៉ាប់រងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ"។ សិទ្ធិនេះក៏ត្រូវបានធានានៅក្នុងប្រទេសកម្ពុជាផងដែរតាមរយៈបញ្ញត្តិទូទៅ និងជាក់លាក់ ដែលមានចែងនៅក្នុងលិខិតូបករណ៍មួយចំនួន រួមមានក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

# សារសំខាន់



ការជំនុំជម្រះដោយយុត្តិធម៌ គឺពិតជាមានសារសំខាន់ជាសារវន្តដើម្បីការពារសិទ្ធិជនជាប់ចោទ និងជនរងគ្រោះព្រមទាំងសម្រាប់ធានាការគ្រប់គ្រងយុត្តិធម៌ប្រកបដោយភាពត្រឹមត្រូវ។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាគន្លឹះក្នុងការការពារសិទ្ធិមនុស្ស និងនីតិរដ្ឋ។

យុត្តិធម៌ត្រូវមាននៅគ្រប់ដំណើរការតុលាការទាំងអស់ ដោយធានាឱ្យបាននូវភាពយុត្តិធម៌ជាអាទិភាពចម្បង។ មានតែជនមានពិរុទ្ធភាពប៉ុណ្ណោះ ដែលត្រូវបានផ្តន្ទាទោស និងកាត់ទោសឱ្យជាប់ពន្ធនាគារ ហើយជនគ្មានទោសត្រូវមានសិទ្ធិចូលរួមនៅក្នុងសង្គមដោយសេរីដោយគ្មានបុរេវិនិច្ឆ័យ។ ហេតុដូច្នេះការមិនគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌អាចនាំឱ្យមានការសម្រេចក្តីដោយអយុត្តិធម៌ ជាពិសេសការផ្តន្ទាទោសដោយមិនត្រឹមត្រូវ។



# ដែនកំណត់



សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវតែអនុវត្តដោយគ្មានករណីលើកលែងឡើយ។ ជនគ្រប់រូបដែលរងការចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌត្រូវមានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌គ្រប់ពេលវេលា រួមទាំងនៅក្នុងអំឡុងស្ថានភាពនៃគ្រាអាសន្ន និងស្ថិតក្នុងស្ថានភាពមានជម្លោះប្រដាប់អាវុធ។

ទោះបីជាមិនស្ថិតនៅក្នុងចំណោមសិទ្ធិបដិប្បញ្ញត្តិ ដែលមានចែងនៅក្នុងមាត្រា ៤ នៃ (ក.ស.អ.ព.ន) ក៏ដោយ ករណីលើកលែងទូទៅនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌គឺមិនអាចបដិសេធបានឡើយ ហើយត្រូវតែអនុវត្តឱ្យស្របតាមគោលបំណងនៃ (ក.ស.អ.ព.ន)។ អាស្រ័យហេតុនេះ ការអនុវត្តទាំងឡាយដែលងាកចេញពីគោលការណ៍ជាមូលដ្ឋាននៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានហាមឃាត់គ្រប់ពេលវេលា។



ខែកញ្ញា ឆ្នាំ២០២២

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights
Sweden Sverige
People Change the World Diakonia

CC BY NC SA